# ជួយសង្គ្រោះផ្កាថ្មរបស់យើង

## ការគ្រប់គ្រងធនធានជលផល ដោយសហគមន៍នៅប្រទេសកម្ពុជា



# រឿងសង្ខេប

សុខា និង ធីតា ជាមិត្តរួមថ្នាក់នឹងគ្នា។ ពួកគេរស់នៅលើកោះមួយនៅក្នុងប្រទេសកម្ពុជា និងមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ដោយបានទៅហែលទឹកកំសាន្តជាលើកដំបូង។

ខណៈដែលពួកគេចុះហែលទឹកមើលផ្កាថ្ម ស្រាប់តែពួកគេបែរជាស្រងាកចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលបានឃើញទៅវិញ។ ផ្កាថ្មត្រូវបានបំផ្លាញ ហើយមានត្រីតិចតួចប៉ុណ្ណោះនៅក្នុងទឹក។ នៅពេលពួកគេលើកឡើងពីបញ្ហានេះជាមួយអ្នកនេសាទពីរនាក់នោះ បែរជាមានប្រតិកម្មយ៉ាងខ្លាំងពីពួកគាត់ទៅវិញ។

តើពួកគេអាចនឹងបញ្ចុះបញ្ចូលប្រជាសហគមន៍ឲ្យជួយការពារធនធានធម្មជាតិក្នុងតំបន់របស់ពួកគេបានដែរឬទេ?



**សុខា**

សុខា ជាសិស្សវិទ្យាល័យ មានអាយុ១៤ឆ្នាំ។ សុខាទើបចូលរៀនថ្ងៃដំបូង និងរីករាយជាមួយការសិក្សាយ៉ាងខ្លាំង។ សុខាមានចំណាប់អារម្មណ៍ទៅហែលទឹកមើលផ្កាថ្ម ពីព្រោះគេចង់ដឹងយ៉ាងខ្លាំងអំពីបរិស្ថានជុំវិញកោះ។



**ធីតា**

ធីតា ជាសិស្សវិទ្យាល័យ មានអាយុ១៥ឆ្នាំ។ ឪពុករបស់នាងជាអ្នកនេសាទ ហើយនាងចូលចិត្តផ្សងព្រេងខ្លាំងណាស់។ ធីតាចាប់អារម្មណ៍ទៅហែលទឹកមើលផ្កាថ្ម ព្រោះនាងទើបតែបានអានសៀវភៅមួយក្បាលទាក់ទងអំពីផ្កាថ្ម។



**លោកតា**

កាលពីនៅក្មេងគាត់ជាអ្នកនេសាទម្នាក់។ គាត់ពិបាកចិត្ត ពេលឃើញគេនេសាទត្រី ព្រោះថាក្នុងជំនាន់របស់គាត់ងាយស្រួលនេសាទត្រី ហើយក៏មិនមានការបំពុលច្រើនដូចសព្វថ្ងៃនេះទេ។ គាត់ចង់ការពារបរិស្ថានធម្មជាតិខ្លាំងណាស់។


សួស្តីធីតា! តើឯង
រីករាយឬទេ ពេលមក
លេងទឹកលេងដូច្នេះ?
ចាស! ខ្ញុំពិតជាចង់ឃើញ
ត្រី និងផ្កាថ្មដែលយើង
ទើបតែបានរៀនហើយ!
ខ្ញុំក៏អញ្ចឹងដែរ!
តុះ! យើងឆាប់ចុះ
ទៅក្នុងទឹកទៅ!
សុខា និងធីតានាំគ្នារត់សំដៅចុះក្នុងទឹក
ពីរបីនាទីក្រោយមកពួកគេមានអារម្មណ៍មិនសប្បាយចិត្ត
ដោយសារ ផ្កាថ្មដែលពួកគេឃើញខុសពីការគិតទៅវិញ


ធីតា! តើឯងមានឃើញដូចខ្ញុំដែរឬអត់? ផ្កាថ្មរងការបំផ្លាញស្ទើរតែទាំងអស់ ហើយមានត្រីងាប់ជាច្រើន!
ចាស! ខ្ញុំឃើញហើយ ប៉ុន្តែខ្ញុំឆ្ងល់ខ្លាំងណាស់ ថាតើត្រីទាំងអស់ហ្នឹងបាត់ទៅណាអស់ហើយ?
ទូកដ៏ធំមួយបានអូសសំដៅមកជិតពួកគេ
អ្នកនេសាទកំពុងបោះចោលកាកសំណល់ និងបំណែកអួនចាស់ៗចូលទៅក្នុងទឹក
មើលចុះ! អ្នកនេសាទទាំងនោះកំពុងតែបំផ្លាញផ្កាថ្មអស់ហើយ! អញ្ចឹងតើ បានជាអ្វីៗគ្រប់បែបយ៉ាងនៅទីនេះងាប់គ្មានសល់! តុះ! យើងនាំគ្នាទៅនិយាយជាមួយពួកគាត់មើល៍ដើម្បីឲ្យដឹងច្បាស់ពីអ្វីដែលកំពុងកើតឡើង។
ពួកគេក៏ហែលសំដៅទៅកាន់ទូកនេសាទនោះ


អ្នកនេសាទមានការភ្ញាក់ផ្អើលពេលឃើញក្មេងទាំងពីរនាក់នៅក្នុងទឹក
ជម្រាបសួរពូ! តើពូដឹងទេថា អ្នូនរបស់ពូកំពុងតែបំផ្លាញផ្កាថ្ម និងចាប់យកកូនត្រីតូចៗ ដែលពូមិនអាចយកទៅហូបបាន?
បើអញ្ចឹង តើវាយ៉ាងម៉េច? សព្វថ្ងៃហ្នឹង គេពិបាករកត្រីខ្លាំងណាស់ ដូច្នេះហើយយើងចាំបាច់ត្រូវប្រើឧបករណ៍នេសាទប្រភេទនេះដើម្បីចាប់ត្រីឲ្យបានច្រើនសម្រាប់ហូប និងលក់នៅលើទីផ្សារ។
ប៉ុន្តែ បើពូធ្វើអញ្ចឹង ពូនឹងកាន់តែពិបាករកត្រីនៅថ្ងៃក្រោយជាមិនខាន! ពូកំពុងតែបំផ្លាញជម្រកត្រី ហើយចាប់យកកូនត្រីតូចៗដូច្នេះ នោះពួកវានឹងមិនអាចធំឡើងបានទេ។
តើឯងចេះស្អី? ពួកឯងគ្រាន់តែជាក្មេងមិនទាន់ដឹងអីទេ! ឆាប់ចេញពីទីនេះភ្លាម យើងចាប់ពួកឯងទាំងពីរនាក់ឥឡូវហ្នឹង!


ភ្លាមនោះក្មេងទាំងពីរក៏ហែលចេញពីទីនោះ ត្រឡប់មកកាន់ឆ្នេរខ្សាច់វិញ
ពូនេសាទនោះ ពិតជាគម្រោះគម្រើយមែន!
មែនហើយ! ពួកគាត់មិនចេះស្រលាញ់បរិស្ថានទាល់តែសោះ។ តុះ! យើងទៅជួបលោកតារបស់ខ្ញុំវិញ ក្រែងគាត់អាចជួយបានខ្លះ។
ថ្ងៃបន្ទាប់មកពួកគេក៏នាំគ្នាទៅផ្ទះលោកតារបស់សុខា
ជម្រាបសួរ លោកតា!
លើកដៃ ថ្វាយព្រះចៅ!
ចៅបានទៅហែលទឹកលេងកាលពីម្សិលមិញ ដើម្បីមើលផ្កាថ្ម ប៉ុន្តែចៅបានឃើញ ត្រីងាប់ជាច្រើនហើយ ផ្កាថ្មត្រូវបំផ្លាញខ្ទេចខ្ទីអស់។
មែនហើយណាចៅវាជារឿងដែលគួរឲ្យសោកស្តាយខ្លាំងណាស់។ តាចាំបានថាកាលតានៅពីក្មេង តាបានទៅនេសាទត្រីនៅទីនោះ តាធ្លាប់ចាប់បានត្រីធំៗរាល់តែលើកហ្នឹង។ ពេលតាហែលទឹក តាបានឃើញ.....


.....អណ្ដើកសមុទ្រធំៗ ផ្សោត ជ្រូកទឹក និងផ្កាថ្មជាច្រើន។ តែឥឡូវហ្នឹង អ្នកនេសាទចាប់បានតែត្រីតូចៗតែប៉ុណ្ណោះ។
តើយើងគួរតែដោះស្រាយបញ្ហានេះដូចម្ដេចទៅលោកតា? តើអ្នកណាជាអ្នកការពារផ្កាថ្មទាំងនេះ?
កូនប្រុសម្នាក់របស់យាយរស់នៅក្នុងភូមិមួយ ដែលមានសហគមន៍នេសាទមួយក្រុមជាអ្នកការពារផ្កាថ្ម។ ប្រជាសហគមន៍ធ្វើការរួមកម្លាំងគ្នាដើម្បីថែរក្សា ការពារត្រី ដើម្បីឲ្យប្រជានេសាទអាចបន្តការនេសាទប្រកបដោយនិរន្តរភាព។
នេះពិតជាគំនិតល្អមែន! តុះ! យើងនាំគ្នាទៅជួបនិយាយជាមួយពួកគាត់មើល៍ក្រែងពួកគាត់អាចជួយអ្វីយើងបាន!
នាថ្ងៃបន្ទាប់អ្នកភូមិរៀបចំកិច្ចប្រជុំបង្កើតក្រុមស្ថាបនិកពិភាក្សាលើការបង្កើតសហគមន៍នេសាទ
សហគមន៍នេសាទអាចផ្ដល់ផលប្រយោជន៍យ៉ាងច្រើនសម្រាប់សហគមន៍ទាំងមូល។ សមាជិកសហគមន៍ទាំងអស់អាចគ្រប់គ្រងលើធនធានរបស់ខ្លួន។
មន្ត្រីជលផល


ប៉ុន្តែតើ
សហគមន៍នេសាទផ្តល់
ផលប្រយោជន៍ឲ្យយើង
ដោយរបៀបណា?


សហគមន៍នេសាទ
មានផលប្រយោជន៍
ច្រើនណាស់ដូចជា...


បង្កើនទិន្នផលនេសាទសម្រាប់សហគមន៍


ទប់ស្កាត់បទល្មើសនេសាទ ដូចជាគ្រឿងផ្ទុះ និង អួនអូសទឹករាក់


បង្កើតតំបន់អភិរក្ស (ហាមឃាត់)


ប៉ុន្តែ
តើសហគមន៍នេសាទ
ស្វែងរកថវិកាដោយ
របៀបណា?


សហគមន៍នេសាទ
អាចស្វែងរកថវិកា
ពីប្រភពផ្សេងៗដូចជា...
ការបង់វិភាគទានពីសមាជិកសហគមន៍
ឬការចូលរួមកម្លាំងដោយស្ម័គ្រចិត្ត
ម្ចាស់ជំនួយ និងសម្បុរសជននានា
សេវាមុជទឹកកំសាន្ត
មជ្ឈមណ្ឌលទេសចរណ៍
TOURIST CENTRE
និងការលក់សំបុត្រចូលទស្សនា
របស់ភ្ញៀវទេសចរណ៍ជាដើម។










"យើងទាំងអស់គ្នាអាចជួយការពារផ្កាថ្ម ដូច្នេះអ្នកជំនាន់ក្រោយក៏អាចរីករាយជាមួយវាផងដែរ៕"



ចប់

# តើអ្វីជាសហគមន៍នេសាទ ?

សហគមន៍នេសាទ សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយឬច្រើន ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានយល់ព្រមសហការគ្នាចូលរួមដោយស្ម័គ្រចិត្ត ក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលប្រកប ដោយនិរន្តរភាព និងការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរ ។

រដ្ឋាភិបាលអាចផ្តល់ផ្នែកនៃដែននេសាទទឹកសាប និងដែននេសាទសមុទ្ររបស់រដ្ឋទៅ ឲ្យសហគមន៍ ឬក្រុមប្រជាពលរដ្ឋដែលរស់នៅក្នុង ឬក្បែរដែននេសាទដើម្បីប្រើប្រាស់ ជាប្រពៃណីដោយប្រជាពលរដ្ឋបង្កើតជាសហគមន៍នេសាទ។

សហគមន៍នេសាទ គ្រប់គ្រងដោយគណៈកម្មការសហគមន៍នេសាទដែលបានជាប់ឆ្នោត ដោយមានការគាំទ្រពីសមាជិកសហគមន៍នេសាទទាំងមូល។

ដែននេសាទសហគមន៍ ត្រូវបានផ្តល់សិទ្ធិសម្រាប់ការនេសាទលក្ខណៈគ្រួសារ ដោយ ប្រើប្រាស់បច្ចេកទេសនេសាទប្រពៃណី ដូចជាការប្រើលប មង និងសន្ទូចជាដើម។

ការនេសាទជាលក្ខណៈសិប្បកម្ម និងឧស្សាហកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងអួនអូស ត្រូវបានហាមឃាត់ក្នុងដែននេសាទសហគមន៍។ សមាជិកសហគមន៍នេសាទធ្វើការ កំណត់បទបញ្ញាផ្ទៃក្នុងរបស់ខ្លួនអនុលោមតាមច្បាប់ស្តីពីជលផល។ ឧបករណ៍នេសាទ ខុសច្បាប់ត្រូវបានហាមឃាត់ជាដាច់ខាត ដូចជាឧបករណ៍ឆក់ គ្រឿងផ្ទុះ សារធាតុពុល គ្រប់ប្រភេទ កាំភ្លើងឬអាវុធកែច្នៃ ការនេសាទដោយប្រើពន្លឺភ្លើង ឬការនេសាទដោយ ពាក់ឧបករណ៍មុជទឹកឬម៉ាស៊ីនខ្យល់ និងឧបករណ៍នេសាទទំនើបឬឧបករណ៍នេសាទ ដែលបង្កើតថ្មី។

ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិបង្កើតសហគមន៍នៅក្នុងតំបន់របស់ខ្លួនតាមរយៈ ការចូលរួមដោយស្ម័គ្រចិត្ត។ ដំណើរការបង្កើតសហគមន៍ត្រូវអនុវត្តន៍ជាជំហានៗ តាមគោលការណ៍របស់រាជរដ្ឋាភិបាលដូចខាងក្រោម ៖




The Rufford Foundation
FAUNA & FLORA INTERNATIONAL
shallowaters
DARWIN INITIATIVE
PRINCE ALBERT II OF MONACO FOUNDATION

# នាំមកជូនដោយ

**អ្នកអភិរក្សបៃតង** គឺជាក្រុមអ្នកបរិស្ថានវ័យក្មេង ប្រចាំកោះស្តេចនៃប្រទេសកម្ពុជា។ អ្នកអភិរក្សបៃតងមានបំណងលើកកម្ពស់ការយល់ដឹងពីបញ្ហាសហគមន៍តំបន់ឆ្នេរ ដូចជាការបំពុល និងការនេសាទលើសកម្រិត។ តាមរយៈការបង្កើតសម្ភារៈថ្មីៗ ដូចជា វីដេអូខ្លី សៀវភៅរឿងរូបភាព អ្នកអភិរក្សបៃតងសង្ឃឹមថានឹងអាចផ្តល់ជាដំបូន្មានល្អៗដល់យុវជនខ្មែរជំនាន់ក្រោយឲ្យជួយការពារធនធានធម្មជាតិរបស់ពួកគេ។

**សាល់ឡូវ៉ាត់ធ័រ** គឺជាសហគ្រាសសង្គមអភិរក្សសមុទ្រមួយ ធ្វើការឆ្ពោះទៅកាន់កម្មវិធីគ្រប់គ្រងផ្កាថ្ម ដោយសហគមន៍ពីសម្រស់កោះស្តេចនៃប្រទេសកម្ពុជា។ តាមរយៈការអប់រំ ការពង្រឹងសមត្ថភាព ការផ្សព្វផ្សាយ សាល់ឡូវ៉ាត់ធ័រមានបំណងឲ្យសហគមន៍មូលដ្ឋានមានសមត្ថភាពក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេជាមួយទិសដៅផ្សារភ្ជាប់ការអភិរក្សជីវៈចម្រុះ ជាមួយនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ** (FFI) គឺជាអង្គការអភិរក្សអន្តរជាតិ ដែលមានតួនាទីការពារប្រភេទ ដែលទទួលរងការគំរាមកំហែង ព្រមទាំងការពារប្រព័ន្ធអេកូឡូស៊ីលើពិភពលោកដោយធ្វើការជ្រើសរើសរកដំណោះស្រាយណា ដែលមាននិរន្តរភាពផ្អែកតាមលក្ខណៈវិទ្យាសាស្ត្រ និងតម្រូវការរបស់មនុស្សជាតិ។ អង្គការ FFI កំពុងដំណើរការនៅក្នុងប្រទេសជាង៤០នៅលើពិភពលោក ដែលភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងទិសដៅជួយសង្គ្រោះប្រភេទសត្វ និងរុក្ខជាតិ ផុតពីការវិនាសផុតពូជ និងជួយសង្គ្រោះជម្រកធម្មជាតិពីការបំផ្លិចបំផ្លាញ ស្របពេលជាមួយនឹងការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាសហគមន៍។ អង្គការ FFI បង្កើតឡើងក្នុងឆ្នាំ១៩០៣ ដែលជាស្ថាប័នអភិរក្សអន្តរជាតិដ៏មានវ័យចំណាស់ជាងគេនៅលើពិភពលោក។ ចាប់តាំងពីឆ្នាំ១៩៩៦អង្គការនេះបានចាប់ផ្តើមអនុវត្តសកម្មភាពរបស់ខ្លួនយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា។

# SAVING OUR REEFS



Script and storyboard: Owen Jones and Catriona Regnier-McKellar

Artwork: Our Books Cambodia

Acknowledgements: We would like to thank Sorn Srenh, Megan Clavier and the members of the Green protectors for their creative input, as well as Berry Mulligan, Chea Phallin, Yos Katank, Deap Polin, Kim Sokha, Sarah Wilson and Luca Budello for editing.

Fauna & Flora International benefits from the support of the Prince Albert II of Monaco Foundation (http//www.fpa2.com)

Shallow Waters benefits from the support of The Rufford Foundation (http://www.rufford.org/)

shallowWaters

FAUNA & FLORA INTERNATIONAL

The Rufford Foundation

DARWIN INITIATIVE

PRINCE ALBERT II OF MONACO FOUNDATION